ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១៣៤/២៥ សជក.

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមិថុនា និងទិសដៅខែកក្កដា ឆ្នាំ២០២៥

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសាកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងសង្គ្រាមប្រដាប់អាវុធដ៏រ៉ាំរ៉ៃ ដែលជំរុញឱ្យមនុស្សរាប់រយលាននាក់បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាលំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង ដែលប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន និងការកេងប្រវ័ញ្ចជាច្រើនរូបភាព។

ការផ្សព្វផ្សាយយ៉ាងទូលំទូលាយរបស់បណ្តាញសារព័ត៌មាននានា ទាំងពិត ទាំងមិនពិត អំពីបទល្មើសជួញដូរមនុស្សនៅកម្ពុជា ព្រមទាំងការចោទប្រកាន់ពីបណ្តាប្រទេស ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការនៃចរន្តសេដ្ឋកិច្ចជាតិ និងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានាក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុស ក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ ចំនួនដ៏ច្រើនលើសលប់នៃប្រជាជនពេញវ័យការងារបានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបកាន់តែមានប្រសិទ្ធភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ។

នៅក្នុងខែមិថុនានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី-ខេត្ត ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួន នៃផែនការយុទ្ធសាស្ត្រជាតិ ដោយប្រឈមនឹងស្ថានភាពប្រែប្រួលឥតឈប់ឈរនៃបទល្មើស។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការយល់ដឹងតាមកម្មវិធីផ្សេងៗ សរុបចំនួន ១៥.៣៣០លើក មានអ្នកចូលរួមសរុបចំនួន ៨៦៤.៦៣៧នាក់ ស្រី ៤៥៧.៩៨១នាក់ (ប្រៀបធៀបនឹងខែមុន មានចំនួន ៨៧០.២៦១នាក់) ថយចុះប្រមាណ ០,៦៤% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ០១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៤.៩៤៨ | ៨០៩.៩៤២ | ៤២៩.១០៤ |
| ០២ | កម្មវិធីផ្សេងៗ | ៣៨២ | ៥៤.៦៩៥ | ២៨.៨៧៧ |
| សរុប | | ១៥.៣៣០លើក | ៨៦៤.៦៣៧នាក់ | ៤៥៧.៩៨១នាក់ |
| *(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៧២ | ២៤.០០៧ | ១១.៥៩៨ | ៣១ | ២.៤៣៥ | ១.១៦០ |
| ២ | កណ្តាល | ៣៥៦ | ៩.៦២០ | ៥.៧៣១ | ០៧ | ៤.០៣៦ | ១.៩០៣ |
| ៣ | បាត់ដំបង | ១.០២៦ | ៥០.៥៥២ | ២៧.៥០១ | ៧៣១ | ២៥.៣៩២ | ១៤.០៦១ |
| ៤ | ពោធិ៍សាត់ | ៥៤១ | ៦៧.៤១៦ | ៣៤.០៦៧ | ៣៦២ | ១៦.៨៣៨ | ៨.៣៤៨ |
| ៥ | សៀមរាប | ៧៤៩ | ៥៦.៥៤៨ | ៣៤.៩២៤ | ៧១៦ | ២៩.៣៨០ | ១៨.៣៨៤ |
| ៦ | កំពង់ឆ្នាំង | ៧១២ | ២៦.១៥៥ | ១៣.៩០៦ | ៣៥៧ | ១២.៧៦១ | ៦.៩៥៦ |
| ៧ | កំពង់ចាម | ១.៦៨៩ | ៩៦.៥២០ | ៤៩.២៨៩ | ០១ | ១៨០ | ១០៥ |
| ៨ | ព្រះសីហនុ | ១៥៣ | ៧.៤៤៩ | ៣.៥៣០ | ៣៦ | ២.៣២៥ | ១.១៤៤ |
| ៩ | ព្រះវិហារ | ០៧ | ៦០២ | ៣៥៩ | | | |
| ១០ | ស្វាយរៀង | ៣៩២ | ២០.៦២៦ | ១១.២៤៩ | ៥០៨ | ១៦.៩៦០ | ១១.២៨៩ |
| ១១ | ប៉ៃលិន | | | | ១០០ | ៣.៨១៧ | ១.៨៥៩ |
| ១២ | កោះកុង | ១.១៩៤ | ១៨.១០០ | ៨.៩៨៥ | ៣៥២ | ៦.៦៦៣ | ៣.៣២៦ |
| ១៣ | កំពត | | | | | | |
| ១៤ | កំពង់ធំ | ៥៥៦ | ៤០.៣៣១ | ២៣.៦៣៤ | ២៥០ | ៩.៨០២ | ៥.៨៤៤ |
| ១៥ | តាកែវ | ៦ | ៧៨.២២១ | ៣៦.៦២៥ | | | |
| ១៦ | ក្រចេះ | ៥៧ | ១.៧០០ | ៦៧៣ | | | |
| ១៧ | កែប | | | | | | |
| ១៨ | កំពង់ស្ពឺ | ៩៧ | ៩.៩៩៥ | ២.៣៨៤ | ៤៣១ | ១៩.៤០៨ | ១០.២៩៦ |
| ១៩ | ស្ទឹងត្រែង | ១៩៣ | ១១.៩៧៥ | ៥.៨៦១ | ១៤៦ | ៤.៩៨៧ | ២.៨៦១ |
| ២០ | រតនគិរី | ៥៨៨ | ២៣.៨០៩ | ១១.៨៨៣ | ២៥១ | ១៤.៤០០ | ៥.៨៥១ |
| ២១ | ព្រៃវែង | ១.០៨០ | ៥៤.៧២១ | ៣០.៩៨៧ | ៧២៨ | ២៣.៤៩២ | ១២.៦៨៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២២ | ត្បូងឃ្មុំ | ០៥ | ៧៤២ | ៤៣៦ | ១៥៧ | ៤.៦២១ | ២.១៨៦ |
| ២៣ | បន្ទាយមានជ័យ | | | | | | |
| ២៤ | ឧត្តរមានជ័យ | ១៤៦ | ៧.០៨៨ | ៤.០៩៥ | ១៩ | ១.៤៨៩ | ៨០៥ |
| ២៥ | មណ្ឌលគិរី | ១៣០ | ៤.២០៣ | ២.០១៨ | ១៦ | ៥៧៦ | ៣០៦ |
| សរុប រាជធានី-ខេត្ត | | ៨.៦២០លើក | ៥១៩.១៥៥នាក់ | ២៧៣.៧៨៥នាក់ | ៤.៥៨៦លើក | ១៦៨.៣២៤នាក់ | ៩៥.១៧០នាក់ |
| សរុបរួម | | ១៣.២០៦លើក | | ៦៨៧.៤៧៩នាក់ | | ៣៦៨.៩៥៥នាក់ | |

❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០១ | ១៥៥ | ៦៧ |
| ២ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០២ | ២៣៤ | ៥២ |
| ៣ | ខេត្តកណ្ដាល | ០៧ | ៦៦៧ | ២១៤ |
| ៤ | ខេត្តបាត់ដំបង | ០៧ | ៤.៨០០ | ២.៣៧៣ |
| ៥ | ខេត្តសៀមរាប | ៧៦ | ៤.៤០៤ | ៣.២៧៤ |
| ៦ | ខេត្តត្បូងឃ្មុំ | ០៤ | ២៩០ | ១៧០ |
| ៧ | ខេត្តឧត្តរមានជ័យ | ១១០ | ៤.០៧៦ | ២.៣៦៤ |
| ៨ | ខេត្តកំពង់ធំ | ១៥ | ១.៥៨៩ | ១.០០៥ |
| ៩ | ខេត្តតាកែវ | ៦០ | ៣០.៦៤៦ | ១៥.០៧៧ |
| ១០ | អង្គការ Friend Insertional និង A21 (សៀមរាប) | ៩៦ | ១.៥៧៥ | ៧៦៦ |
| ១២ | អង្គការសាម៉ារីតាន់ភឺស(បាត់ដំបង) | ០៤ | ៦.២៥៩ | ៣.៥១៥ |
| *សរុប* | | *៣៨២លើក* | *៥៤.៦៩៥នាក់* | *២៨.៨៧៧នាក់* |

## ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ ការផលិត និងចែកផ្សាយសម្ភារផ្ដល់ព័ត៌មាន និងអប់រំ (IEC = Information Education Communication Materials)

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនលើក | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ២០.០៨៧ប័ណ្ណ | | |
| ២ | បាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១.៦១៧ប័ណ្ណ | | |
| ៣ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ៦១៥ប័ណ្ណ | | |
| | សរុប | | | ២២.៣១៩ប័ណ្ណ | | |

❖ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

| ល.រ | អង្គភាពអនុវត្ត | បណ្ដាញផ្សព្វផ្សាយ | ចំនួនលើក/ដង | ចំនួនមើល |
|---|---|---|---|---|
| ១ | គ.ជ.ប.ជ | -បណ្ដាញទូរស័ព្ទចល័ត | ០១ | |
| ២ | សៀមរាប | -វិទ្យុជាតិ | ១៤៨ | |
| ៣ | កំពង់ចាម | -វិទ្យុជាតិ | ១៥០ | |
| ៤ | ព្រៃវែង | -វិទ្យុជាតិ | ៥០ | |
| ៥ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ៣២ | |
| ៦ | ប៉ៃលិន | -វិទ្យុជាតិ | ៤៩៦ | |
| សរុប | | | ៩៧៧ លើក | |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញផ្តល់បទសម្ភាសន៍តាមប្រព័ន្ធ Zoom Meeting ជាមួយអង្គការ UNICEF ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិ របស់គម្រោង UNICEF PROTECTION PROJECT។

▪ **ខេត្តសៀមរាប៖** លោកអធិការនៃអធិការដ្ឋាននគរបាលស្រុកវ៉ារិន បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទាមតិ របស់វិទ្យុជាតិនគរភ្នំចំនួន០១លើក ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពស្រុកវ៉ារិន ក្នុងឆ្នាំ២០២៤ និងផែនការបន្តឆ្នាំ២០២៥។

▪ **ខេត្តកំពង់ចាម**

- តំណាងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ របស់វិទ្យុជាតិខេត្តចំនួន០១លើក ក្រោមប្រធានបទ ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

- តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិសហគមន៍ ក្រោមប្រធានបទ ផលប៉ះពាល់លើកុមារដោយសារការធ្វើចំណាកស្រុករបស់គ្រួសារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន០២លើក មានអ្នកចូលមើល និងស្តាប់ ប្រមាណ ៨០០នាក់។

▪ **ខេត្តកំពង់ធំ** លោកនាយការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ របស់វិទ្យុជាតិខេត្តចំនួន០១លើក ក្រោមប្រធានបទ ស្តីពីការយល់ដឹង និងរួមគ្នាបង្ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ និងកុមារតាមប្រព័ន្ធអនឡាញ។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ ដូចមានក្នុងតារាងខាងក្រោម៖

| បរិយាយ | ចំនួនមនុស្ស | សញ្ជាតិ |
|---|---|---|
| ស្ត្រីបរទេសជាមួយបុរសខ្មែរ | ០៨នាក់ | ចិន៩៥ កូរ៉េខាងត្បូង៣០(ស្រី០៥) អាម៉េរិក១៦(ស្រី០២) វៀតណាម០៤ អូស្ត្រាលី០៣ បារាំង០៣ ជប៉ុន០៣ ស្វីស០២ ម៉ាឡេស៊ី០២ ប៉ូឡូញ០១ នីហ្សេរីយ៉ា០១ នេប៉ាល់០១ ឡាវ០១ អង់គ្លេស០១ និងនូវែលសេឡង់០១។ |
| បុរសបរទេសជាមួយស្ត្រីខ្មែរ | ១៥៦នាក់ | |
| សរុប | ១៦៤ នាក់ | ១៥ សញ្ជាតិ |

### ខ.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

អគ្គស្នងការដ្ឋាននគរបាលជាតិ បានតាមដាន និងធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់មកវិញ តាមរយៈការប្រមូលទិន្នន័យពីបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស ដូចមានក្នុងតារាងខាងក្រោម៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មិថុនា | ១៣៨.០៣៧នាក់ | ៦២.៤២៥នាក់ | ៤.៧៣៨នាក់ | ១.៤៨៥នាក់ |

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស | | | |
|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មិថុនា | ១៧.៨៨២នាក់ | ៧.៦៤២នាក់ | ២២៨នាក់ | ៨៦នាក់ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

➜ ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន

| ល.រ | រាជធានី-ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៩៥៦ | ៣២៦ | | |
| ២ | បាត់ដំបង | ០៥ | ០០ | ០២ | ០០ |
| ៣ | កោះកុង | ២៦ | ០៤ | | |
| | សរុប | ៩៩១ នាក់ | ៣៣៨ នាក់ | ០៣ នាក់ | ០១នាក់ |

➜ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលពលករខ្មែរចំណាកស្រុកដែលបញ្ជូនត្រឡប់ពីប្រទេសថៃនិរទេស សរុបចំនួន ៥១៥នាក់ (ប្រុស២៨៥នាក់ ស្រី១៦៤នាក់ កុមារា៣០នាក់ កុមារី៣៦នាក់)។

▪ មណ្ឌលទទួលពលករកំរៀង បានទទួលពលករខ្មែរចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃ សរុបចំនួន ៧១នាក់ (ស្រី១៦នាក់ អនីតិជន ០៩នាក់)។

**ខ.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ ការផ្សព្វផ្សាយ

▪ **ខេត្តព្រះវិហារៈ** ចុះផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យឡឥដ្ឋ ក្បឿង និងវិស័យកសិ-ឧស្សាហកម្ម នៅក្នុងស្រុករវៀង ស្រុកជាំក្សាន្ត ស្រុកឆែប និងស្រុកគូលែន បានចំនួន១៦សហគ្រាស មានអ្នកចូលរួម ៥៦៥នាក់ ស្រី២០៤នាក់។

▪ **ខេត្តក្រចេះៈ** ចុះផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋ ចំនួន០១លើក មានអ្នកចូលរួម ១១នាក់ ស្រី០៤នាក់។

▪ **ខេត្តរតនគិរីៈ** ចុះផ្សព្វផ្សាយពីផលប៉ះពាល់នៃ ការរៀបអាពាហ៍ពិពាហ៍វ័យកុមារពលកម្មកុមារ និងការចំណាក់ស្រុក ការទប់ស្កាត់ ការរំលោភបំពានលើកុមារ ការកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអនឡាញ និងការជួញដូរមនុស្ស ដល់ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំកុមារ យុវជន និងកុមារ ក្នុងឃុំល្បាំង១ ឃុំល្បាំង២ ឃុំសេដា សរុបមានចំនួន ១.៥៤៩នាក់ ស្រី ១.០៨០នាក់ ក្នុងនោះកុមារ ៨៣៧នាក់ កុមារី ៥៨៤នាក់។

**ខ.៥. ការលើកកម្ពស់ជីវភាព**

▪ **ខេត្តឧត្តរមានជ័យៈ** មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបើកវគ្គបណ្តុះបណ្តាលជំនាញផុងការហ្វេកម្រិតមូលដ្ឋាន ការថែទាំ និងជួសជុលរថយន្ត សេវាកម្មកុំព្យូទ័រ និងសេវាកម្មសម្អាងកាយ ដល់យុវជនដែលមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ចំនួន០៤លើក មនុស្សចំនួន ១៣៥នាក់ ស្រី៤៥នាក់។

▪ **ខេត្តរតនគិរីៈ** បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកាត់ដេរ និងអ៊ុតសក់-សម្អាងកាយ ជូនដល់ស្ត្រីមេម៉ាយជួបការលំបាក ស្ត្រីទីទ័លក្រ និងក្មេងស្រីបោះបង់ការសិក្សា និងស្ត្រីជាប់ពន្ធនាគារ ០១លើក មានសិស្សសរុបចំនួន ៦៤នាក់ ក្នុងនោះស្ត្រីជាប់ពន្ធនាគារ ចំនួន ២៤នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ១៣ករណី (ប្រៀបធៀបខែឧសភា មានចំនួន ២២ករណី ថយចុះ ០៩ករណី) ស្មើនឹង៤០,៩០% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន ១៨នាក់ (ស្រី០៣នាក់) ជនជាតិចិន ចំនួន០១នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ៣៣នាក់ (ស្រី២៩នាក់) មានអាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ១៤នាក់ និងអាយុ១៨ឆ្នាំឡើង ១១នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ២៤នាក់ គ្រួសារ ០៩នាក់)។ ក្នុងនោះចែកជា៖

**ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ០៣/០៥ករណី (ថយចុះ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៥នាក់ ជនជាតិចិន ០១នាក់។ សង្គ្រោះជនរងគ្រោះ ០៤នាក់ មានអាយុ១៨ឆ្នាំឡើង ០៤នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ០៤នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | ចិន១ | ០២ |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | | ០១ |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ០១ | ០២ | | ០១ |
| *សរុប* | *០៣ ករណី* | *០៥ នាក់* | *០១ នាក់* | *០៤ នាក់* |

**ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១០/១៧ករណី (ថយចុះ០៧ករណី) ឃាត់ខ្លួនជនសង្ស័យ ១៣នាក់ (ស្រី០៣នាក់)។ សង្គ្រោះជនរងគ្រោះ ២៩នាក់ (ស្រី២៩នាក់) មានអាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ១៤នាក់ និងអាយុ១៨ឆ្នាំឡើង ០៧នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ២០នាក់ គ្រួសារ ០៩នាក់)។

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៣ | ២០ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ០៨ | ០៧ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ |
| សរុប | ១០ ករណី | ១៣ នាក់ | ២៩ នាក់ |

## ឃ. កិច្ចការពារជនរងគ្រោះ

### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ពីក្រៅប្រទេស សរុបចំនួន ៣៨នាក់ (ប្រុស០១នាក់ ស្រី២៦នាក់ កុមារី១១នាក់)។ *ក្រោយពីទទួលបានការកំណត់អត្តសញ្ញាណ ពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញ រកឃើញជនរងគ្រោះ ចំនួន ៣៤នាក់(ស្រី២៤នាក់ កុមារី១០នាក់)។*

- ប្រទេសចិន ចំនួន ៣៣នាក់(ស្រី២៣នាក់ កុមារី១០នាក់) អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទ:។

- ប្រទេសថៃ ចំនួន ០៥នាក់ (ប្រុស០១នាក់ ស្រី០៣នាក់ កុមារី០១នាក់) កេងប្រវ័ញ្ចកម្លាំងពលកម្ម លើទូកនេសាទ០១នាក់(ស្រី) និងបុគ្គលសង្ស័យថារងគ្រោះ០៤នាក់(ប្រុស០១នាក់ ស្រី០២នាក់ កុមារី០១នាក់)។

**ឃ.២. ការផ្តល់សេវា**

▪ មន្ទីរកិច្ចការនារីខេត្តព្រះសីហនុ ដោយទទួលកិច្ចសហការពីស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងអង្គការម្លប់តាប៉ាង បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្តដល់កុមារីរងគ្រោះដោយអំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ចំនួន ០៣នាក់ ព្រមទាំងឧបត្ថម្ភថវិកាម្នាក់ ១០០,០០០រៀល និងសម្ភារៈប្រើប្រាស់របស់អង្គការ UNFPA មួយចំនួន។

**ឃ.២. ការស្តារនីតិសម្បទា**

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ សរុបចំនួន ៣៨នាក់(ប្រុស០១នាក់ ស្រី២៦នាក់ កុមារី១១នាក់)៖ ទទួលសេវាពីអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ០៩នាក់ អង្គការអាដហុក០២នាក់ អង្គការហាការអន្តរជាតិ០៥នាក់ អង្គការរតនៈអន្តរជាតិ១១នាក់ និងអង្គការសម្ព័ន្ធចាប់ដៃ០៦នាក់ មជ្ឈមណ្ឌលស្តារនីតិសម្បទាប៉ោយប៉ែត០៣នាក់ និងទៅសហគមន៍០២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**<br>-បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ដល់មន្ត្រីជួរមុខតាមបណ្តាប៉ុស្តិ៍គរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិ និងប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ក្នុងមូលដ្ឋានស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបង ០១លើក<br>-បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី និងបុគ្គលិកស្ម័គ្រចិត្ត នៅមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ០១លើក | ០២ | ៦១ | ១០ |
| ២ | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**<br>-សហការជាមួយអង្គការម៉ារីស៊ី បើកវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងច្បាប់គតិយុត្តពាក់ព័ន្ធ ០១លើក<br>-បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការកសាងសំណុំរឿង និងបញ្ជ្រាបការងារយេនឌ័រ ជូនដល់មន្ត្រីជំនាញនាយកដ្ឋាន | ០១<br><br>០១ | ៨០<br><br>៦០ | ៣០<br><br>១០ |
| ៣ | **ខេត្តកណ្តាល៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បា បានសហការជាមួយនាយកដ្ឋានកិច្ចការពារកុមារ រដ្ឋបាលក្រុងតាខ្មៅ ស្រុកកៀនស្វាយ ស្រុកកណ្តាលស្ទឹង ស្រុកអង្គស្នួល និងអង្គការសកម្មភាពដើម្បីកុមារ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ដល់ គ.ក.ស.ក ក្រុង/ស្រុក ប្រធានការិយាល័យសង្គមកិច្ចក្រុង/ស្រុក មេឃុំ អ.ក.ន.ក មេភូមិ/អនុភូមិ ប្រជាការពារ ឪពុក ម្តាយកុមារ | ០១ | ១២៥ | ៥១ |
| ៥ | **ខេត្តកំពង់ស្ពឺ៖** មន្ទីរកិច្ចនារីខេត្ត បានសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព | ០១ | ៣៨ | ២៩ |

| | | | | |
|---|---|---|---|---|
| ៦ | ខេត្តត្បូងឃ្មុំ៖ មន្ទីរកិច្ចការនារី មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអង្គការណូមីណេតរើក បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទីផ្សារការងារ | ០២ | ២៩០ | ១៧០ |
| ៧ | ខេត្តក្រចេះ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការ APLE បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី ការបង្ការទប់ស្កាត់ និងការឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ | ០១ | ៦៥ | ៣៦ |
| ៨ | ខេត្តរតនគិរី៖ បណ្តុះបណ្តាលស្តីពី ការឆ្លើយតបសេវា និងការថែទាំ សុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដល់លោក លោកស្រី ជាសមាជិក សមាជិកាក្រុមការងារ GBV | ០១ | ១១២ | ៤៦ |
| | សរុប | ១០វគ្គ | ៨៣១នាក់ | ៣៨២នាក់ |

**ក.២. សិក្ខាសាលានៅក្នុងប្រទេស**

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយគម្រោងJICA រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការធ្វើបច្ចុប្បន្នភាព «បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌល» គម្រោងការអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះ ដែលរួចពីការជួញដូរមនុស្ស មានសិក្ខាកាមចូលរួមចំនួន ៦០នាក់ ស្រី ៣៣នាក់។

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយអង្គការ APLE រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ មានសិក្ខាកាមចូលរួមចំនួន ៥៥នាក់ ស្រី ៤៥នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំចំនួន ០៧លើក អ្នកចូលរួមចំនួន ៨៥នាក់ ស្រី ១៦នាក់ ក្នុងនោះមាន៖

- កិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាបន្ត លើផែនការសកម្មភាពសម្រាប់ការអនុវត្តស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស រវាងកម្ពុជា-ថៃ ចំនួន០១លើក នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួម ៣១នាក់ ស្រី០៧នាក់
- កិច្ចប្រជុំកម្រិតបច្ចេកទេស ពិភាក្សា និងពិនិត្យឯកសារគតិយុត្ត សម្រាប់ប្រជុំទ្វេភាគីបន្ត លើផែនការសកម្មភាពរួម ក្នុងការអនុវត្តស្តង់ដារនីតិវិធីប្រតិបត្តិ (SOP) ស្តីពីកិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់ ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ចំនួន០១លើក នៅខេត្តសៀមរាប អ្នកចូលរួមចំនួន ៧៥នាក់ ស្រី ១២នាក់
- កិច្ចប្រជុំជាមួយអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីពិគ្រោះយោបល់ ត្រៀមរៀបចំសិក្ខាសាលា ស្តីពីយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ ចំនួន០១លើក អ្នកចូលរួមចំនួន ២៥នាក់ ស្រី ០៥នាក់
- កិច្ចប្រជុំផ្ទៃក្នុង៖ ពិនិត្យរបាយការណ៍សមិទ្ធកម្ម ក្រុមការងារគណនេយ្យ នៃការិយាល័យផែនការហិរញ្ញកិច្ច និងភស្តុភារ នៃលេខាធិការដ្ឋានរដ្ឋបាលសរុប ចំនួន០១លើក។ ប្រជុំកែសម្រួលរបាយការណ៍ឆមាសទី១ ឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន០១លើក។ ប្រជុំស្តីពីរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការជាមួយរដ្ឋសមាជិកអាស៊ាន និងដៃគូពិគ្រោះយោបល់ ក្នុងក្របខ័ណ្ឌអាស៊ាន ចំនួន ០១លើក និងប្រជុំកែសម្រួលអំពីរបៀបវារៈលើសេចក្តីព្រាង ស្តីពីផែនការសកម្មភាព សម្រាប់អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) ចំនួន ០១លើក មានអ្នកចូលរួមសរុបចំនួន ២៩នាក់ ស្រី ០៤នាក់។

▪ **ខេត្តសៀមរាប៖** បានរៀបចំកិច្ចប្រជុំ ចំនួន១៤លើក គឺលេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន ៦៤នាក់ ស្រី៣៨នាក់ និងកិច្ចប្រជុំរបស់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក ចំនួន១៣លើក អ្នកចូលរួមចំនួន២៦១នាក់ ស្រី១៦៤នាក់។

▪ **ខេត្តតាកែវ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំង និងការទប់ស្កាត់អំពើជួញដូរមនុស្សខុសច្បាប់ នៅក្នុងក្រុមហ៊ុន ចំនួន០២លើក អ្នកចូលរួមចំនួន៣៤នាក់។

▪ **ខេត្តកណ្តាល៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារ ស្តីពីការចុះធ្វើវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅតាមបណ្តាក្រុង/ស្រុក ចំនួន០១លើក អ្នកចូលរួមចំនួន១០នាក់ ស្រី០៥នាក់។

▪ **ខេត្តកំពង់ធំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ០២លើក គឺ ប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន៥០នាក់ ស្រី២៣នាក់ និងកិច្ចប្រជុំ ស្តីពីការងារទំនាក់ទំនង និងការពង្រឹងលើការងារទប់ស្កាត់ការការពារអំពើជួញដូរស្ត្រីនិងកុមារ និងយន្តការគ្រប់គ្រងក្មេងគេចសាលាចំនួន០១លើក អ្នកចូលរួមចំនួន៩២នាក់ ស្រី១៣នាក់។

❖ **ការចូលរួមសន្និសីទ សិក្ខាសាលា កិច្ចប្រជុំក្រៅប្រទេស**

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានចូលរួមសិក្ខាសាលា CTIP LEAP លើកទី២ រៀបចំដោយកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ក្នុង Module4 នៅប្រទេសវៀតណាម ចំនួន០១លើក និងចូលរួមក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្ម ឆ្លងដែន លើកទី២៥ និងកិច្ចប្រជុំពាក់ព័ន្ធ (25th SOMTC and Its Related Meetings) នៅប្រទេសម៉ាឡេស៊ី ចំនួន០១លើក។

- លោកស្រីវរសេនីយ៍ឯក **ថោង សុវត្តី** អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ បានចូលរួមក្នុងកិច្ចពិភាក្សាអំពី តួនាទី ភារកិច្ចរបស់ក្រុមការងារកាត់ផ្តាច់បណ្តាញឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការរត់ពន្ធមនុស្ស និងអំពើជួញដូរមនុស្ស (DWG) នៃដំណើរការ Bali Process នាទីក្រុងបាងកក ប្រទេសថៃ ចំនួន០១លើក។

▪ **ខេត្តសៀមរាប** លោកស្រីស្នងការរងនគរបាលខេត្ត និងជាប្រធានក្រុមការងារកិច្ចការអនុវត្តច្បាប់ បានទៅចូលរួមកិច្ចសន្ទនាថ្នាក់តំបន់ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្រោមប្រធានបទ " **កិច្ចសហប្រតិបត្តិការទៅជាសកម្មភាព**" នៅប្រទេសឥណ្ឌូនេស៊ី។

### ខ.២. ជំនួបពិភាក្សាការងារ

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំ ក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលជួបពិភាក្សាការងារ ជាមួយ៖

- នាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ស្តីពីកិច្ចសហការក្នុងការអនុវត្តគម្រោងពង្រឹងសមត្ថភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដើម្បីការពារពលករចំណាកស្រុក នៅទីស្តីការក្រសួងមហាផ្ទៃ

- ឯកឧត្តម ឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ី ប្រចាំនៅកម្ពុជា ដើម្បីពង្រឹងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។

- លោក Andrew Leyva ប្រតិភូតំណាងស្ថានទូតអាម៉េរិកប្រចាំកម្ពុជា ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ។

▪ ខេត្តសៀមរាប៖ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការ IJM ស្តីពីការសិក្សានិងពិគ្រោះយោបល់ក្នុងការកសាងគម្រោងពង្រឹងសមត្ថភាព ដល់មន្ត្រី គ.ខ.ប.ជ និងក្រុមការងារបច្ចេកទាំង៦។

▪ ខេត្តកំពង់ចាម៖

-លោកជំទាវ អភិបាលរងខេត្ត បានដឹកនាំតំណាងក្រុមការងារជំនាញទាំង៦ នៃគណកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ចូលរួមកិច្ចប្រជុំជំនួបពិភាក្សាជាមួយអង្គការ IJM ដើម្បីពិគ្រោះយោបល់ក្នុងការកសាងគម្រោងពង្រឹងសមត្ថភាពដល់មន្ត្រី គ.ខ.ប.ជ និងក្រុមការងារជំនាញទាំង៦។

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានទទួលជួបគណៈប្រតិភូមកពីស្ថានទូតអាម៉េរិក ដើម្បីស្វែងយល់ពីស្ថានភាពពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម។

▪ ខេត្តកំពង់ធំ៖ លោកជំទាវ អភិបាលរងខេត្ត បានដឹកនាំប្រធានក្រុមការងារទាំង៦ ទទួលជួបពិភាក្សាជាមួយអង្គការ IJM ដើម្បីពិភាក្សាអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ២១លើក។ (ឧបសម្ព័ន្ធ)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើ វិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យចកល្វែង ។
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

### គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែកក្កដា ឆ្នាំ ២០២៥

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែក ការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំង និយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៣. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៤. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៥. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដាន ការអនុវត្ត

៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៧. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល

៩. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ..សុក្រ..១៤..កើត..ខែ..ស្រាពណ៍.. ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី...៨... ខែ...សីហា....ឆ្នាំ២០២៥
**អនុប្រធានអចិន្ត្រៃយ៍**

**ជូ_ប៊ុនអេង**

**ចម្លងជូន**
-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ
**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**
-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
**"ដើម្បីជូនជ្រាប"**
-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ
## ការងារដឹកនាំ និងសម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

-ដឹកនាំប្រតិភូគណៈកម្មការសាខាសមាគមនារី ក្រសួងមហាផ្ទៃ ចូលជួបសម្តែងការគួរសម និងគោរពជូនពរ ឯកឧត្តម អភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ ប្រធានកិត្តិយស

-ជាអធិបតីក្នុងពិធីអបអរសាទរខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-កិច្ចប្រជុំគណៈកម្មការខ្លឹមសារ ដើម្បីរៀបចំមហាសន្និបាតវិសាមញ្ញសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នៅវិមាន៧មករា

-កិច្ចប្រជុំផ្សព្វផ្សាយព្រឹត្តិការណ៍ និងគោលការណ៍សំខាន់ៗ ដោយសង្ខេបប្រចាំសប្តាហ៍ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ

-បានដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះពិនិត្យស្ថានភាព និងសួរសុខទុក្ខ មន្ត្រីនិងករកម្លាំងជួរមុខ នៅតាមបណ្តាច្រកទ្វារអន្តរជាតិ កម្ពុជា-ថៃ នៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន

-កិច្ចប្រជុំអន្តរក្រសួង ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-កិច្ចប្រជុំផ្សព្វផ្សាយព្រឹត្តិការណ៍ និងគោលការណ៍សំខាន់ៗ ដោយសង្ខេបប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

-ពិធីប្រគល់សញ្ញាបត្រ និងវិញ្ញាបនបត្រជូនដល់និស្សិតជ័យលាភី ថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនគរបាលជំនាន់ទី១ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រនគរបាល ជំនាន់ទី១១ ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រនគរបាលជំនាន់ទី១២ ថ្នាក់បរិញ្ញាបត្រជំនាញគ្រប់គ្រងពន្ធនាគារ ជំនាន់ទី៣ និងសិស្សនគរបាលវគ្គបណ្តុះបណ្តាល កម្រិតបឋមវិជ្ជាជីវៈនគរបាល ជំនាន់ទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅបណ្ឌិត្យសភានគរបាលកម្ពុជា

-ក្នុងពិធីបិទសិក្ខាសាលាបូកសរុប និងផ្សព្វផ្សាយលទ្ធផលការងារ SOMTC-កម្ពុជា ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន SOMTC-កម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ

-អមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីចូលរួមចែករំលែកបទពិសោធន៍ និងបង្ហាញអំពីរចនាសម្ព័ន្ធរបស់ គ.ជ.ប.ជ និង គ.ខ.ប.ជ ដល់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) នៅការិយាល័យរបស់អង្គការ IJM ភ្នំពេញ

-អមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដឹកនាំគណៈប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមអបអរបុណ្យជាតិរបស់ប្រទេសហ្វីលីពីន និងទំនាក់ទំនងមិត្តភាព រវាងកម្ពុជា-ហ្វីលីពីន ក្រោមអធិបតីភាព លោកជំទាវ **ចម និមល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងភាគីហ្វីលីពីន តំណាងដោយលោកជំទាវ Flerida Ann Camille P. Mayo ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំកម្ពុជា នៅសណ្ឋាគារ Shangrila ភ្នំពេញ

-ដឹកនាំមន្ត្រីជាន់ខ្ពស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផល កិច្ចប្រជុំគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-ថៃ (JBC) និងការងារពាក់ព័ន្ធកិច្ចការព្រំដែនក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដឹកនាំដោយ ឯកឧត្តម ហ៊ូ សាគុណ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

-លិខិតរបស់ គជ.ប.ជ.៖ លិខិតចេញ(២២ច្បាប់) លិខិតចូល(១៤ច្បាប់)

-លិខិតរបស់អគ្គលេខាធិការដ្ឋាន គជ.ប.ជ.៖ លិខិតចេញ(២៨ច្បាប់) លិខិតចូល(២៤ច្បាប់)

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

-បានចូលរួមពិធីបិទសិក្ខាសាលាបូកសរុប និងផ្សព្វផ្សាយលទ្ធផលការងារ SOMTC-កម្ពុជា ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន SOMTC-កម្ពុជា នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

-បានរៀបកិច្ចប្រជុំពិភាក្សាប្រមូលធាតុចូលលើសន្ធានុក្រម ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់ទម្រង់ ចំនួន០២លើក នៅសាលប្រជុំ គ.ជ.ប.ជ

-បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារ ដើម្បីការងារពីការកេងប្រវ័ញ្ចផ្លូវភេទ និងរំលោភបំពាន និងការឆ្លើយតបប្រកបដោយសុខដុមរមនា ចំពោះការកេងប្រវ័ញ្ចផ្លូវភេទ និងរំលោភបំពានតាមរយៈ វិធីសាស្រ្ត ឧបត្ថម្ភគាំទ្រ ដោយអង្គការសហប្រជាជាតិប្រចាំកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា

-បានចូលរួមសិក្ខាសាលា ផ្សព្វផ្សាយសៀវភៅណែនាំ ស្តីពីនីតិវិធីប្រតិបត្តិ កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ នៅសណ្ឋាគារ សាន់អេនមូន។

▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

-បានប្រជុំពិនិត្យ និងបញ្ចូលសូចនាកររបស់ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ នៃ គ ជ.ប.ជ.ទៅក្នុងតារាងផែនការសកម្មភាពរបស់ក្រុមការងារទេសន្តរប្រវេសន៍ ដើម្បីអនុវត្តផែនការណ៍យុទ្ធសាស្រ្តជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៦ ឆ្លើយតបតាមសំណើររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**

-បានប្រជុំក្នុងក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ស្តីពីការពង្រឹងវិន័យរបស់កងកម្លាំង ការងារបូកសរុបរបាយការណ៍ និងទិសដៅអនុវត្តបន្តក្នុងត្រីមាសទី៣ ឆ្នាំ២០២៥

-បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការការពារការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ សម្រាប់ដៃគូរដ្ឋាភិបាល។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ និងអន្តរជាតិ**

-បានចូលរួមពិធីបិទសិក្ខាសាលាបូកសរុប និងផ្សព្វផ្សាយលទ្ធផលការងារ SOMTC-កម្ពុជា ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន SOMTC-កម្ពុជា នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។